# មេរៀនទី ៦៣៖ ព្រះយេស៊ូវ បន្ទ្រាបព្យុះ

## [ម៉ាកុស ៤៖ ៣៥-៤១]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/6nRtG9oVhyk

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/rM3ojTlicZY

**គោលបំណង៖** សូមងាយបែបរកព្រះយេស៊ូវនៅពេលដែលអ្នកភ័យខ្លាច

**ខគម្ពីរចងចាំ៖** *យ៉ូស្វេ១៖៩ "តើអញមិនបានបង្គាប់ឯងទេឬអីដូច្នេះចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុត ចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែងណាដែលឯងទៅផង"។*

**ចំរៀង** ( *យូធូបលីង* )៖

១.មានព្រះគ្រីស្ទគង់ក្នុងទូក https://youtu.be/2eORYd5n2l8

២.បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0

៣ ពេលខ្យល់ព្យុះបក់ខ្លាំង https://youtu.be/lI5A7jKQb2o

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ទូកសង្គ្រោះជីវិត»

សម្ភារៈដែលត្រូវការ៖ ក្រដាសរាម



១. ដាក់ក្រដាសរាមរាងជារង្វង់ នៅលើឥដ្ឋ ក្រដាសប្រៀបដូចជាទូកអីចឹង។

២. ចាក់បទចម្រៀង ហើយឲ្យកុមាររាំនៅជុំវិញរង្វង់។ នៅពេលដែលបទចម្រៀងឈប់ កុមារទាំងអស់ត្រូវឡើងជាន់លើក្រដាសនោះ។ ប៉ុន្តែប្រសិនបើកុមារណាមិនអាចឡើងជាន់លើក្រដាសបាន កុមារនោះនឹងចាញ់ល្បែងនេះ។

៣. ដកក្រដាសមួយចេញ(ត្រូវដកក្រដាសចេញមួយ រាល់ពេលដែលចម្រៀងឈប់ម្តង)។ ហើយបន្តលេងល្បែងនេះទៀត។

៤. នៅពេលដែលក្រដាសនៅសល់តែមួយសន្លឹក ហើយកុមារណាដែលអាចជាន់លើក្រដាសនោះបានគឺជាអ្នកឈ្នះ។

### ៤. ការណែនាំមេរៀន

សូមលើកដៃឡើងប្រសិនបើអ្នកមិនដែលមានការភ័យខ្លាច។(រុញ) ពេលខ្លះពួកយើងទាំងអស់គ្នាសុទ្ធតែជួបការភ័យខ្លាច។នៅក្នុងព្រះគម្ពីរបានប្រាប់យើងថា ព្រះតែងតែការពារ និងថែរក្សាយើងឲ្យមានសុវត្ថិភាព មិនថានៅពេលដែលយើងភ័យខ្លាចឬមានការព្រួយបារម្ភក៏ដោយ។ ថ្ងៃនេះយើងនឹងរៀនអំពី ពួកសាវក ដែលពួកគេមានការភ័យខ្លាច និងពីរបៀបដែលព្រះយេស៊ូវសង្គ្រោះពួកគេ។

សូមឲ្យគ្រូបាននិយាយរឿងនេះប្រាប់កុមារ ក្រុមទីមួយសូមជួយធ្វើសម្លេងរលកសមុទ្រនិងព្យុះបក់បោក។ ហើយក្រុមមួយទៀតដើរតួជាពួកសាវកដែលភ័យខ្លាច។សូមបង្ហាញពីការទទួលខុសត្រូវរបស់ក្រុមនីមួយៗ ហើយឲ្យពួកគេសម្តែងសាកល្បង។

- ក្រុមទី១ (សមុទ្រ)៖ កុមារត្រូវងើបគូទ ហើយយោលខ្លួនចុះឡើង រួចធ្វើជាសំឡេងខ្យល់ បក់បោក



- ក្រុមទី២ (ពួកសាវក)៖ កុមារត្រូវដាក់ដៃលើថ្ពាល់សងខាង ហើយធ្វើដូចជាយំ "អត់ទេ! ពួកយើងទាំងអស់គ្នានឹងត្រូវស្លាប់ហើយ!" ។
- ជ្រើសរើសកុមារម្នាក់ឲ្យដើរតួជាព្រះយេស៊ូវ ហើយឲ្យគេដេកចាប់តាំងពីសាច់រឿងនៅក្នុងព្រះគម្ពីរ រហូតដល់ក្រុមទី២ ដាស់គេឲ្យភ្ញាក់។

នៅពេលដែលគ្រូចង្អុលក្រុមរបស់អ្នកមានន័យថា ក្រុមរបស់អ្នកគឺត្រូវសម្តែងតាមតួនាទី។ សូមស្តាប់ ហើយធ្វើតាមតួនាទីក្រុមរបស់អ្នក និងស្រែកឲ្យឮតាមតែអាចធ្វើទៅបាន។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅល្ងាចមួយបន្ទាប់ពីការអធិប្បាយរួចមក ព្រះយេស៊ូវបានសម្រេចចិត្តធ្វើដំណើរតាមទូកនេសាទជាមួយនឹងពួកសាវករបស់ទ្រង់ ដើម្បីឆ្លងកាត់សមុទ្រទៅកាន់ត្រើយម្ខាងទៀត។(**ចង្អុលក្រុមទី១**)

នៅពេលដែលពួកគេធ្វើដំណើរបានពាក់កណ្តាលសមុទ្រ ក៏ចាប់ផ្តើមានព្យុះបក់បោកជាមួយរលកសមុទ្រ។ (**ចង្អុលក្រុមទី១**)

ហើយទូកក៏បានបក់ទៅមុខ ទៅក្រោយ ឡើងលើ ចុះក្រោមតាមរលកសមុទ្រ។ ព្យុះគឺរឹតតែខ្លាំង ហើយកាន់តែគ្រោះថ្នាក់ទៅៗ ។( **ចង្អុលក្រុមទី១**)

ព្រះយេស៊ូវបានផ្ទំលក់តាំងពីពេលទូកចាប់ផ្តើមចេញពីច្រាំង។ ទោះជាសមុទ្រធ្វើឲ្យទូកគ្រលែងយ៉ាងណាក៏ដោយ ក៏ទ្រង់នៅតែផ្ទំលក់ដែរ។ ប៉ុន្តែពួកសិស្សរបស់ព្រះអង្គចាប់ផ្តើមភ័យខ្លាច។ (**ចង្អុលទៅក្រុមទី ២**)

ពួកគេបានព្យាយាមទំលាក់ក្តោងឲ្យទាប ហើយបោះយុថ្កាចូលទឹក ប៉ុន្តែមិនបានផលអ្វីឡើយ។ ទូកស្ទើរតែលិចទៅហើយ។ (**ចង្អុលទៅក្រុមទី ២**)

ទីបំផុតពួកសិស្សមិនអាចទ្រាំទ្របានទៀតទេ។ ព្រះយេស៊ូវនៅតែផ្ទំលក់ស្រួល ដូច្នេះពួកសិស្សក៏ដាស់ទ្រង់ឲ្យភ្ញាក់។ ពួកសិស្សនិយាយថា "តើលោកគ្រូមិនខ្វល់ថាយើងនឹងលង់ទឹកទេឬអី?" ។ (**ចង្អុលទៅក្រុមទី ១ និងក្រុមទី ២**)

(**ក្រុមទី២ស្រែកដាស់ព្រះយេស៊ូវឲ្យភ្ញាក់ឡើង / ក្រុមទី២ចង្អុលទៅកុមារដែលដើរតួជា ព្រះយេស៊ូវឲ្យក្រោកឈរឡើង**)

ពេលនោះ ព្រះយេស៊ូវក្រោកឈរឡើងក្នុងទូក ហើយស្រែកថា៖ «ស្ងាត់! នៅឲ្យស្ងៀម!" ខ្យល់ព្យុះបានឈប់ ហើយរលកបានស្ងប់ (**ក្រុមទី១និងក្រុមទី២នៅស្ងៀម**) ហើយទូកដែលព្រះយេស៊ូវគង់នោះក៏មានសុវត្ថិភាពវិញ។

ព្រះយេស៊ូវបានសម្លឹងមើលទៅសិស្សរបស់ទ្រង់ដែលសើមខ្លួនជោក ហើយកំពុងតែញ័រភ័យនោះ។ រួចទ្រង់មានព្រះបន្ទូលថា **ម៉ាកុស ៤៖៤០** "ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម៉្លេះ ម្តេចក៏គ្មានសេចក្តីជំនឿអីចឹង" ។

នោះគេមានសេចក្តីស្ញែងខ្លាចជាខ្លាំង ទាំងសួរគ្នាទៅវិញទៅមកថាដូច្នេះថា **ម៉ាកុស ៤៖៤១** "តើលោកនេះ ជាអ្វី បានជាខ្យល់ និងសមុទ្រក៏ស្តាប់បង្គាប់លោកដូច្នេះ" ។

ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ ដែលជាអ្នកបង្កើតសកលលោកនេះ។ យើងអាចពឹងលើទ្រង់ដើម្បីបញ្ឈប់ព្យុះក្នុងជីវិតយើងបាន។ ពេលយើងមានការភ័យខ្លាច ឬការព្រួយបារម្ភ នោះយើងអាចអង្វររកព្រះយេស៊ូវដោយការអធិស្ឋាន ហើយយើងដឹងថាទ្រង់បានឮពីការអធិស្ឋានរបស់យើង ដូចជាទ្រង់បានឮសម្រែករបស់ពួកសិស្សឲ្យជួយដែរ។

## ៦. សំនួរពិភាក្សា

១. តើអ្នកគិតថាពួកសិស្សខ្លាចអ្វីជាងគេ? *(ខ្យល់ព្យុះ លិចទូក ស្លាប់)*
២. តើពួកសិស្សស្វែងរកនរណាពេលពួកគេភ័យខ្លាច? *(ព្រះយេស៊ូវ)*
៣. តើព្រះយេស៊ូវបានធ្វើឲ្យខ្យល់ព្យុះស្ងប់ដោយរបៀបណា? *(ព្រះអង្គបានកំហែងទៅកាន់ព្យុះ)*
៤. តើអ្នកមានការភ័យខ្លាចអ្វីខ្លះ? *(ឱ្យកុមារឆ្លើយ)*
៥. តើព្រះយេស៊ូវអាចបញ្ឈប់ការភ័យខ្លាចរបស់អ្នកបានទេ? តើអ្នកគិតថាព្រះអង្គបានធ្វើដូចម្តេច? *(ឱ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ឆ្លងទន្លេ»

សម្ភារៈ ដែលត្រូវការ៖ ក្រដាសរ៉ាមពីរសន្លឹក



១. ចែកកុមារជាក្រុមដែលមានគ្នាពី ៥ ទៅ ៦ នាក់
២. ឲ្យក្រុមនីមួយៗឈរជាជួរ នៅចំហៀងម្ខាងនៃថ្នាក់រៀន
៣. ឲ្យក្រដាសរាមពីរសន្លឹកទៅក្រុមនីមួយៗ
៤.ក្រុមនីមួយៗត្រូវផ្លាស់ទីពីជ្រុងម្ខាងខាងនៃថ្នាក់រៀនទៅកាន់ជ្រុងម្ខាងទៀត នៃថ្នាក់រៀន ដោយជាន់លើក្រដាសរាមតែពីរសន្លឹកតែប៉ុណ្ណោះ។
៥. ហើយក្រុមណាដែលអាចផ្លាស់ទីសមាជិកក្រុមអស់មុនគេ ក្រុមនោះជាអ្នកឈ្នះ។

## ៨. ខគម្ពីរចងចាំ

***យ៉ូស្វេ១៖៩*** *"តើអញមិនបានបង្គាប់ឯងទេឬអីដូច្នេះចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុត ចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែងណា ដែលឯងទៅផង"។*

## ៩. ហត្ថកម្ម «ព្រះយេស៊ូវ បង្ក្រាបព្យុះ»

សម្ភារៈដែលត្រូវការ៖ ចានក្រដាស ដងឈើ ក្រដាសពណ៌ ថ្នាំលាប ឬក្រមួន កាវ កន្ត្រៃ



១. ចាប់ផ្តើមដោយកាត់ចានក្រដាសជាពីរពាក់ កណ្តាល ហើយធ្វើជា "រលកទឹក" នៅតាម គែមចាន។ (យើងនឹងប្រើពាក់កណ្តាលទៀតដើម្បីចងទៅខាងក្រោយដូច្នេះកុំបោះវាចោល។)
***គ្រូអាចប្រើដបទឹកសុទ្ធ ឬកែវកាហ្វេ(ក្រដាស)ជំនួសចានក្រដាសបាន។*



២. លាបពណ៌ខៀវលើចានក្រដាសនោះ ហើយយកចានក្រដាសដាក់ជាប់គ្នា ដោយទុកកន្លែងទំនេរច្រើននៅបាតចាន ដើម្បីឲ្យទូកអាចផ្លាស់ទីជាមួយនឹងដងឈើបាន។

៣. កាត់រាងត្រីកោណ និងរាងទូក ហើយបិទវាលើដងឈើ។



៤. ដាក់ដងឈើនៅចន្លោះចានក្រដាសហើយផ្លាស់ទីវា ដើម្បីចាប់ផ្តើមអុំទូក!

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើអ្នកខ្លាចអ្វីជាងគេនៅក្នុងជីវិតរបស់អ្នក? ក្នុងនាមយើងជាមនុស្ស យើងមានការភ័យខ្លាចជាច្រើន។ អ្នកខ្លះ បារម្ភពីសុខភាព អ្នកខ្លះខ្លាចបរាជ័យក្នុងជីវិត។ នៅពេលណាដែលការភ័យខ្លាចព្យាយាមគ្របសង្កត់អ្នក វាជារឿងសំខាន់ដែលត្រូវចងចាំថា ព្រះយេស៊ូវគឺជាអ្នកបង្កើតសកលលោកនេះ ហើយទ្រង់យកចិត្តទុកដាក់ចំពោះអ្នក។ ព្រះអង្គស្គាល់ឈ្មោះរបស់អ្នក និងចំនួនសក់នៅលើក្បាលរបស់អ្នក។ កុំឈប់ជឿព្រះយេស៊ូវ! សូមចាំខគម្ពីរចងចាំរបស់យើងមុនពេលអ្នកចាប់ផ្តើមបង្រៀននៅថ្ងៃនេះ៖ ព្រះមានបន្ទូលថា **ទំនុកដំកើង ៩១៖១៤** *“ ដោយព្រោះវាបានយកអញជាទីស្រឡាញ់នោះអញនឹងជួយឲ្យរួច អញនឹង តាំងឡើងយ៉ាងខ្ពស់ពីព្រោះវាបានស្គាល់ឈ្មោះអញ ”*។